**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ ៤៩៤-សល-១៧ អអក

ភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
## ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់អគ្គិសនីកម្ពុជា

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជនរស់នៅក្នុងឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណរបស់អគ្គិសនីកម្ពុជា ដើម្បីអនុញ្ញាតឲ្យបន្ថែមតំបន់ចែកចាយអគ្គិសនីលើតំបន់ចែកចាយដែលមានស្រាប់ តាមខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណ ដូចមានជូនភ្ជាប់មកជាមួយនេះ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែសម្រួលអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជន មានសិទ្ធិពិនិត្យ ផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាលើខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណ ដែលគ្រោងផ្តល់ជូនអគ្គិសនីកម្ពុជា ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណនៅ................................................................................................................................សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជនរស់នៅក្នុងឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យអគ្គិសនីកម្ពុជា អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះរហូតដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា **"អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ"** ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ទី នរិទ្ធ**

សេចក្តីព្រាង

អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA

ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
ELECTRICITY LAW OF THE KINGDOM OF CAMBODIA

# សេចក្តីសម្រេចកែសម្រួលលើកទី២៦
# លើឯកសារអាជ្ញាបណ្ណលេខ ០០១ ឯអ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០២ របស់អគ្គិសនីកម្ពុជា
# សម្រាប់ការបន្ថែមតំបន់ចែកចាយ

# DECISION ON TWENTY SIXTH REVISION

TO THE LICENSE DOCUMENT No. 001 LD DATED FEBRUARY 01, 2002 ISSUED TO ELECTRICITÉ DU CAMBODGE

**FOR ADDING DISTRIBUTION AREAS**

ថ្ងៃទី ខែ ឆ្នាំ២០១៧
.. .. , 2017

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អអក
EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**
ELECTRICITY AUTHORITY OF CAMBODIA
លេខ ៖ -១៧-អអក

# សេចក្តីសម្រេចកែសម្រួលលើកទី២៦ លើឯកសារអាជ្ញាបណ្ណលេខ 001 ឯអ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០២ សម្រាប់អគ្គិសនីកម្ពុជា

# DECISION ON TWENTY SIXTH REVISION TO THE LICENSE DOCUMENT No. 001 LD DATED FEBRUARY 01, 2002 ISSUED TO ELECTRICITÉ DU CAMBODGE

## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

-អនុវត្តតាមមាត្រា ៧ និង ៣០ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-In exercise of the powers conferred by Article 7 and 30 of the Electricity Law promulgated by the Royal Decree No. NS/RKM/0201/03 dated February 2, 2001

-យោងឯកសារអាជ្ញាបណ្ណរបស់អគ្គិសនីកម្ពុជា លេខ 001 ឯអ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០២

-Refer to the License Document of Electricité du Cambodge No. 001 LD dated February 01, 2002

-យោងប្រកាសរបស់ក្រសួងរ៉ែ និងថាមពល លេខ ៤៥១ រ៉េ. អថ. ប្រក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤

- In accordance with PRAKAS of Ministry of Mines and Energy N° 451 dated November 13, 2014.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី ខែ ឆ្នាំ២០១៧ ដល់ថ្ងៃទី ខែ ឆ្នាំ២០១៧

-In accordance with the consultation with concerned parties and public, made from , 2017 to , 2017

-យោងតាមការអនុម័តរបស់សម័យប្រជុំ**អាជ្ញាធរអគ្គិសនីកម្ពុជា**លើកទី នៅថ្ងៃទី ខែ ឆ្នាំ២០១៧

-In accordance with the decision of Electricity Authority of Cambodia's Session No. Dated , 2017